**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Ministry of Labour and Vocational Training

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៣០២ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយក នាយិកា នៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាធារណៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ឆាប់ទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រយកទៅប្រើប្រាស់ ក្រសួងស្នើ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយក នាយិកា រៀបចំបោះពុម្ពវិញ្ញាបនបត្រ ឬសញ្ញាបត្រ និងដាក់ស្នើមកក្រសួង ដើម្បីធ្វើការត្រួតពិនិត្យ និងសុំហត្ថលេខា យ៉ាងយូររយៈពេល០៦ខែ បន្ទាប់ពីលទ្ធផលប្រឡងបញ្ចប់ការសិក្សារបស់សិស្ស-និស្សិត ត្រូវបានប្រកាសជាផ្លូវការ។ ក្នុងករណីមានការយឺតយ៉ាវ ក្រសួងមិនទទួលខុសត្រូវឡើយ។ ចំពោះការដាក់ស្នើមកក្រសួង ត្រូវធ្វើឡើងតាមរយៈនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា ដោយភ្ជាប់មកជាមួយនូវសំណុំបែបបទ និងឯកសារពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

- លិខិតស្នើសុំចុះហត្ថលេខាលើសន្លឹកវិញ្ញាបនបត្រ ឬសញ្ញាបត្រ
- បញ្ជីឈ្មោះសិស្ស-និស្សិតដែលបានប្រឡងបញ្ចប់ការសិក្សាជាប់ជាស្ថាពរ(ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- បញ្ជីឈ្មោះសិស្ស-និស្សិតដែលបានជ្រើសរើស ឬប្រឡងជ្រើសរើសឲ្យចូលរៀនជាប់ជាស្ថាពរ (ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- វិញ្ញាបនបត្រ សញ្ញាបត្រ ឬសញ្ញាបត្រសមមូល (ត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវ ឬមានតម្លៃស្មើ) របស់សិស្ស-និស្សិត ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវ មុនពេលចូលសិក្សា និងពេលកំពុងសិក្សា។ វិញ្ញាបនបត្រ សញ្ញាបត្រ ឬសញ្ញាបត្រសមមូល ត្រូវត្រួតពិនិត្យពីភាពត្រឹមត្រូវ គ្មានការក្លែងបន្លំ ដោយគ្រឹះស្ថានសិក្សាដែលស្នើសុំ។
- ក្នុងករណីបាត់ ឬខូចវិញ្ញាបនបត្រ ឬសញ្ញាបត្រ ដោយប្រការណាមួយ ត្រូវមានលិខិតបញ្ជាក់ពីមូលហេតុបាត់បង់ដោយមានការទទួលដឹងឮពីរដ្ឋអំណាចមូលដ្ឋាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយក នាយិកា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រោមឱវាទទាំងអស់ ចូលរួមសហការ និងអនុវត្តតាមសេចក្តីជូនដំណឹងខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់។៚

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
-គ្រប់អង្គភាពពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់គ្រឹះស្ថាន អ.ប.វ ក្រោមឱវាទក្រសួង
"ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ